# លោកអ្នកប្រហែលជាមានសិទ្ធិទទួលកិច្ចជួយបង្វែរ

កិច្ចជួយបង្វែរ (Diversion Services) អាចផ្តល់ជូនលោកអ្នកជាប្រាក់ឬក៏កិច្ចជួយដែលមិនមែនជាប្រាក់ដើម្បីបំពេញនូវសេចក្តីត្រូវការក្នុងពេលបច្ចុប្បន្នដ៏ជាក់លាក់ ឬការមានភាពអាសន្នមួយ ។ សូមអានសន្លឹកពត៌មាននេះដោយប្រុងប្រយត្ន័ ។ សន្លឹកនេះមានផ្តល់ជូននូវពត៌មានដែលអាចជួយចំពោះលោកអ្នកសំរេច ថាតើកិច្ចជួយបង្វែរនេះត្រឹមត្រូវចំពោះលោកអ្នកឬទេ ។ លោកអ្នកត្រូវតែបំពេញនិងចុះហត្ថលេខានៅលើកិច្ចព្រមព្រៀងជាមួយកិច្ចជួយបង្វែរ (Diversion Services Agreement) នៅមុនពេលដែលលោកអ្នកអាចទទួលកិច្ចជួយបង្វែរនេះ ។

## ពត៌មានអំពីកិច្ចជួយបង្វែរ

- ខណ្ឌជាអ្នកកំណត់ថាតើលោកអ្នកមានសិទ្ធិទទួលកិច្ចជួយបង្វែរឬទេ ។ កិច្ចជួយបង្វែរនេះគឺ**សំរាប់តែ**មនុស្សណាដែល :
  - អាចទទួលនូវផលប្រយោជន៍ពីកិច្ចជួយបង្វែរនេះ និងអាចចៀសវាងសេចក្តីត្រូវការទទួលប្រាក់ជំនួយជារាល់ខែ **និង**
  - បង្ហាញថាជាអ្នកមានសិទ្ធិទទួលប្រាក់ជំនួយ **និង**
  - ត្រូវការជំនួយជាប្រាក់ខ្លះ និងមិនមែនជាប្រាក់ខ្លះដើម្បីជួយដោះស្រាយសេចក្តីត្រូវការក្នុងពេលបច្ចុប្បន្ន ឬស្ថានភាពពេលមានអាសន្ន ។
- លោកអ្នកអាចបានទទួលកិច្ចជួយបង្វែរនេះ**តែ**នៅពេលណាដែលលោកអ្នកដាក់ពាក្យសុំ ។ បើសិនជាលោកអ្នកជ្រើសរើសទទួលប្រាក់ជំនួយ លោកអ្នកនឹងមិនមានសិទ្ធិទទួលកិច្ចជួយបង្វែរបន្តទៅទៀតឡើយ ។
- លោកអ្នកគួរ**តែជ្រើសរើស**ដើម្បីទទួលកិច្ចជួយបង្វែរនេះ បើសិនជាលោកអ្នកមិនត្រូវការ ឬមិនចង់បានប្រាក់ជំនួយនៅក្នុងខែនីមួយៗ ។
- លោកអ្នកប្រហែលជាអាចមានសិទ្ធិទទួលជំនួយខលហ្វ្រេស(CalFresh) និងជំនួយ មេឌី–ខាលនិងលោកអ្នកប្រហែលជាអាចទទួលកិច្ចជួយសំរាប់ការថែរក្សាក្មេង ។
- លោកអ្នកហើយនិងខណ្ឌត្រូវតែព្រមព្រៀងនៅលើរបៀបបង់ប្រាក់ឱ្យសំរាប់កិច្ចជួយបង្វែរនេះ ។

## ការជ្រើសរើសកិច្ចជួយបង្វែរជំនួសប្រាក់ជំនួយប្រចាំខែ

**បើសិនជាលោកអ្នកជ្រើសរើសទទួលកិច្ចជួយបង្វែរ** :

- លោកអ្នកនឹងមិនបានទទួលប្រាក់ជំនួយ**ប្រចាំខែ**ឡើយ ។
- លោកអ្នកត្រូវតែចុះហត្ថលេខានៅលើសំណៅកិច្ចព្រមព្រៀងជាមួយកិច្ចជួយបង្វែរ (Diversion Services Agreement) ដែលដាក់ភ្ជាប់ជាមួយនេះ ។
- លោកអ្នកនឹងទទួលសេចក្តីប្រកាសមួយដែល :
  - បដិសេធពាក្យដាក់សុំប្រាក់ជំនួយក្នុងពេលបច្ចុប្បន្នរបស់លោកអ្នក **និង**
  - ជំរាបលោកអ្នកអំពីរបៀបដែលប្រាក់បង់សំរាប់កិច្ចជួយបង្វែររបស់លោកអ្នក និងចំនួនខែនៃកំឡុងពេលកិច្ចជួយបង្វែររបស់លោកអ្នក ។
- លោកអ្នកនឹងទទួលសេចក្តីប្រកាសយល់ព្រម ឬក៏បដិសេធមួយដោយឡែកសំរាប់ជំនួយដទៃទៀតដែលលោកអ្នកបានដាក់ពាក្យសុំ ដូចជាជំនួយខលហ្វ្រេស(CalFresh) និងជំនួយមេឌី–ខាល ។
- លោកអ្នកត្រូវតែប្រាប់អ្នកកាន់សំណុំរឿងរបស់លោកអ្នក បើសិនជាលោកអ្នកត្រូវការជំនួយសំរាប់កិច្ចថែរក្សាក្មេង នៅក្នុងកំឡុងពេលនៃកិច្ចជួយបង្វែររបស់លោកអ្នក ។

## បន្ទាប់ពីបានទទួលកិច្ចជួយបង្វែរ

បើសិនជាលោកអ្នកដាក់ពាក្យសុំប្រាក់ជំនួយបន្ទាប់ពីទទួលកិច្ចជួយបង្វែរ និងគឺ :

- <u>នៅមុនពេលដែលកំឡុងពេលនៃកិច្ចជួយបង្វែរបញ្ចប់</u> លោកអ្នកត្រូវតែជ្រើសរើសឱ្យខណ្ឌអនុវត្តតាមវិធានការណាមួយដូចខាងក្រោមនេះ :
  - បន្ថយប្រាក់ជំនួយប្រចាំខែរបស់លោកអ្នកតាមចំនួនដែលបានកំណត់ដោយខណ្ឌដើម្បីបង់សងប្រាក់បង់សំរាប់កិច្ចជួយបង្វែរ/កិច្ចការ **ឬ**
  - គិតបញ្ចូលកំឡុងពេលសរុបនៃកិច្ចជួយបង្វែរទៅលើចំនួនកម្រិតពេល៤៨ខែរបស់លោកអ្នក ។
- <u>បន្ទាប់ពីបញ្ចប់កំឡុងពេលនៃកិច្ចជួយបង្វែរ</u> ខណ្ឌនឹងរាប់បញ្ចូលតែចំនួនពេលមួយខែ នៃកំឡុងពេលកិច្ចជួយបង្វែរទៅលើចំនួនកម្រិតពេល៤៨ខែរបស់លោកអ្នកតែប៉ុណ្ណោះ ។

## ការគិតរកចំនួនកំឡុងពេលនៃកិច្ចជួយបង្វែរ

នៅពេលដែលខណ្ឌគិតរកកំឡុងពេលនៃកិច្ចជួយបង្វែរ ខណ្ឌ :

- កំណត់អំពីតម្លៃទិញ ឬតម្លៃនៅក្នុងពេលបច្ចុប្បន្ននៃកិច្ចជួយដែលមិនមែនជាប្រាក់ដែលលោកអ្នកទទួល ។
- ដកចំនួននៃប្រាក់បង់សំរាប់កិច្ចជួយបង្វែរ/កិច្ចការ និងចែកចំនួននេះដោយចំនួនប្រាក់ជំនួយច្រើនបំផុតរបស់លោកអ្នកសំរាប់ក្រុមគ្រួសារទទួលជំនួយរបស់លោកអ្នក នៅក្នុងពេលដែលលោកអ្នកបានទទួលកិច្ចជួយបង្វែរ ។

## ឧទាហរណ៍នៃការគិតរកកំឡុងពេលនៃកិច្ចជួយបង្វែរ

- អ្នកដាក់ពាក្យសុំមានកូនពីរនាក់ទទួលប្រាក់ចំនួន$1,375 ដើម្បីយកមកជួសជុលថែរក្សារថយន្តនៅពេលមានអាសន្ន ដែលអ្នកស្រីនោះអាចបន្តទៅធ្វើការ ។
- ជាមួយប្រាក់ជំនួយច្រើនបំផុតចំនួន $638 សំរាប់ក្រុមគ្រួសារទទួលជំនួយរបស់គាត់ដែលមានគ្នាបីនាក់នៅក្នុងពេលដែលអ្នកស្រីនេះទទួលកិច្ចជួយបង្វែរ ចំនួនកំឡុងពេលនៃកិច្ចជួយបង្វែរគឺមានពីរខែ ($1,375 ត្រូវបានចែកដោយ $638 = 2.1 ខែដែលគេបានសម្រួលបន្ថយទៅចំនួនកំឡុងពេលកិច្ចជួយបង្វែរចំនួនពីរខែ) ។

## បើសិនជាលោកអ្នកមិនបានជ្រើសរើសថាចង់ទទួលកិច្ចជួយបង្វែរនេះទេ សូមប្រាប់ខណ្ឌរបស់លោកអ្នកថាលោកអ្នកចង់ទទួលប្រាក់ជំនួយប្រចាំខែ បើសិនជាលោកអ្នកមានសិទ្ធិទទួល ។